**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.០០៦.......សហវ.......

# សារាចរណែនាំ
## ស្ដីពី
## ការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ

ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការរៀបចំថវិកាសម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងលើកកម្ពស់គុណភាពនៃការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ស្របតាមការចង្អុលទិសនៃឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ និងឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ ដូចខាងក្រោម÷

១. ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកាត្រូវរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ ដោយឆ្លុះបញ្ចាំងអំពីតម្រូវការប្រើប្រាស់ចាំបាច់និងអាទិភាពនៃតម្រូវការចំណាយនិងផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំនេះត្រូវបញ្ជាក់ឈ្មោះគម្រោង តម្លៃគម្រោង វិធីសាស្ត្រលទ្ធកម្ម កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់នៃការអនុវត្តគម្រោង និងកាលបរិច្ឆេទគ្រោងទូទាត់។

២. អង្គភាពប្រើប្រាស់នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកាត្រូវរៀបចំគម្រោងតម្រូវការប្រើប្រាស់ប្រចាំឆ្នាំតាមប្រភេទលទ្ធកម្ម រួមមានលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដោយបញ្ជាក់អំពីបរិមាណ តម្លៃ លក្ខណៈបច្ចេកទេស និងពេលវេលាប្រើប្រាស់ រួចបញ្ជូនឱ្យបានទាន់ពេលវេលាទៅអង្គភាពលទ្ធកម្ម/ក្រុមលទ្ធកម្មដើម្បីប្រមូលសរុបទិន្នន័យនៃតម្រូវការប្រើប្រាស់។

៣. អង្គភាពលទ្ធកម្ម នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងក្រុមលទ្ធកម្មនៃអង្គភាពថវិកាត្រូវរៀបចំជាឡូត៍លទ្ធកម្ម សម្រាប់មុខសញ្ញាលទ្ធកម្មដែលស្ថិតក្នុងប្រភេទដូចគ្នាហើយមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ឬបម្រើឱ្យការងារតែមួយ។ ឡូត៍លទ្ធកម្មដែលមានលក្ខណៈដូចគ្នាឬស្រដៀងគ្នាត្រូវបញ្ចូលជាក្រុមធំមួយហៅថាកញ្ចប់លទ្ធកម្មឬគម្រោងលទ្ធកម្មសម្រាប់ធ្វើលទ្ធកម្មតែមួយលើក បន្ទាប់មកត្រូវគណនាតម្លៃនិងកំណត់វិធីសាស្ត្រលទ្ធកម្មនៃគម្រោងនីមួយៗនោះ។

៤. អង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងក្រុមលទ្ធកម្មនៃអង្គភាពថវិកា ត្រូវរៀបចំជាតារាងគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំតាមគំរូដែលជាឧបសម្ព័ន្ធនៃសារាចរណែនាំនេះ។ ដោយឡែកអង្គភាពថវិកាថ្នាក់កណ្តាលនិងអង្គភាពថវិកាថ្នាក់មូលដ្ឋាននៃស្ថាប័នអនុវត្តលទ្ធកម្មថ្នាក់ជាតិត្រូវបញ្ជូនគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំទៅអង្គភាពលទ្ធកម្មនៃសាមីស្ថាប័នអនុវត្តលទ្ធកម្មដើម្បីបញ្ចូលជាឧបសម្ព័ន្ធនៃគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម តាមគំរូដែលជាឧបសម្ព័ន្ធនៃសារាចរណែនាំនេះ ឱ្យបានក្នុងសប្តាហ៍ទី១ នៃខែមិថុនា មុនឆ្នាំអនុវត្តថវិកា។

៥. ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្ញើគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំភ្ជាប់ជាមួយនឹងសំណើគម្រោងថវិកាប្រចាំឆ្នាំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួនពីរច្បាប់ ដោយមួយច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងមួយច្បាប់ទៀតបញ្ជូនទៅអគ្គនាយកដ្ឋានថវិកា យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមិថុនា មុនឆ្នាំអនុវត្តថវិកា សម្រាប់ជាមូលដ្ឋានក្នុងការចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ កម្រិតបច្ចេកទេសនិងកម្រិតថ្នាក់ដឹកនាំក្រសួងស្ថាប័នជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការខកខានមិនបានភ្ជាប់គម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំជាមួយនឹងសំណើគម្រោងថវិកាប្រចាំឆ្នាំដែលជាសមាសធាតុសំខាន់មួយធ្វើឱ្យការចរចាកញ្ចប់ថវិកាប្រចាំឆ្នាំនឹងមិនអាចប្រព្រឹត្តទៅបាន។

៦. ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកាត្រូវកែសម្រួលគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយកញ្ចប់ថវិកាបន្ទាប់ពីបានឯកភាពក្នុងពេលការពារថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយរៀបចំជាសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដោយត្រូវអនុលោមតាមប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែវិច្ឆិកា ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យនិងអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។

គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកា ត្រូវទទួលបន្ទុកអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ១ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

...ស្ថាប័នអនុវត្តលទ្ធកម្ម...

គណៈកម្មាធិការលទ្ធកម្ម(គ.ល)

## តារាងគម្រោងផែនការលទ្ធកម្ម ប្រចាំឆ្នាំ...
## ទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា

ឯកតាៈលានរៀល

| ល.រ | បរិយាយមុខសញ្ញាលទ្ធកម្ម | តម្លៃគម្រោង | វិធីសាស្ត្រលទ្ធកម្ម | កាលបរិច្ឆេទគ្រោងអនុវត្តគម្រោង | | កាលបរិច្ឆេទ គ្រោងទូទាត់ (ត្រីមាស) | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ចាប់ផ្តើម (ត្រីមាស) | បញ្ចប់ (ត្រីមាស) | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| **ក.លទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម** | | | | | | | |
| | I- លទ្ធកម្មទំនិញ | | | | | | |
| 1 | 1- | | | | | | |
| 2 | 2- | | | | | | |
| 3 | 3- | | | | | | |
| សរុប I | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| | II- លទ្ធកម្មសំណង់ | | | | | | |
| 4 | 1- | | | | | | |
| 5 | 2- | | | | | | |
| 6 | 3- | | | | | | |
| សរុប II | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| | III- លទ្ធកម្មសេវាកម្ម | | | | | | |
| 7 | 1- | | | | | | |
| 8 | 2- | | | | | | |
| 9 | 3- | | | | | | |
| សរុប III | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុប ក | តម្លៃគម្រោង I+II+III | | | | | | |
| | ចំនួនគម្រោង I+II+III | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ខ.លទ្ធកម្មសេវាទីប្រឹក្សា** | | | | | | | |
| 1 | 1- | | | | | | |
| 2 | 2- | | | | | | |
| 3 | 3- | | | | | | |
| សរុប ខ | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| **គ.សរុបរួម** | | | | | | | |
| សរុប ក | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុប ខ | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុបរួម | តម្លៃគម្រោង : ក+ ខ | | | | | | |
| | ចំនួនគម្រោង : ក+ ខ | | | | | | |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦

............ថ្ងៃទី ខែ ឆ្នាំ២០......

**ប្រធានអង្គភាពលទ្ធកម្ម**

បានពិនិត្យ និងឯកភាព

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦

..........ថ្ងៃទី ខែ ឆ្នាំ២០.......

**ប្រធាន(...ឈ្មោះស្ថាប័នអនុវត្តលទ្ធកម្ម...)**

**និងជាប្រធានគណកម្មាធិការលទ្ធកម្ម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

...(ឈ្មោះស្ថាប័នអនុវត្តលទ្ធកម្ម)...

...(ឈ្មោះអង្គភាពថវិកា)..

ក្រុមលទ្ធកម្ម

## តារាងគម្រោងផែនការលទ្ធកម្ម ប្រចាំឆ្នាំ...
## ទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា

ឯកតា:លានរៀល

| ល.រ | បរិយាយមុខសញ្ញាលទ្ធកម្ម | តម្លៃគម្រោង | វិធីសាស្ត្រលទ្ធកម្ម | កាលបរិច្ឆេទគ្រោងអនុវត្តគម្រោង | | កាលបរិច្ឆេទ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ចាប់ផ្តើម (ត្រីមាស) | បញ្ចប់ (ត្រីមាស) | គ្រោងទូទាត់ (ត្រីមាស) | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| **ក.លទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម** | | | | | | | |
| | I- លទ្ធកម្មទំនិញ | | | | | | |
| 1 | 1- | | | | | | |
| 2 | 2- | | | | | | |
| 3 | 3- | | | | | | |
| សរុប I | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| | II- លទ្ធកម្មសំណង់ | | | | | | |
| 4 | 1- | | | | | | |
| 5 | 2- | | | | | | |
| 6 | 3- | | | | | | |
| សរុប II | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| | III- លទ្ធកម្មសេវាកម្ម | | | | | | |
| 7 | 1- | | | | | | |
| 8 | 2- | | | | | | |
| 9 | 3- | | | | | | |
| សរុប III | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុប ក | តម្លៃគម្រោង I+II+III | | | | | | |
| | ចំនួនគម្រោង I+II+III | | | | | | |

| ខ.លទ្ធកម្មសេវាទីប្រឹក្សា | | | | | | | |
|---|---|---|---|---|---|---|---|
| 1 | 1- | | | | | | |
| 2 | 2- | | | | | | |
| 3 | 3- | | | | | | |
| សរុប ខ | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| **គ.សរុបរួម** | | | | | | | |
| សរុប ក | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុប ខ | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុបរួម | តម្លៃគម្រោង : ក+ ខ | | | | | | |
| | ចំនួនគម្រោង : ក+ ខ | | | | | | |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦

............ថ្ងៃទី ខែ ឆ្នាំ២០......

**អ្នកធ្វើតារាង**

បានពិនិត្យ និងឯកភាព

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦

..........ថ្ងៃទី ខែ ឆ្នាំ២០.......

**ប្រធាន (...ឈ្មោះអង្គភាព...)**

**និងជាប្រធានក្រុមលទ្ធកម្ម**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

...ស្ថាប័នអនុវត្តលទ្ធកម្ម...

គណៈកម្មាធិការលទ្ធកម្ម(គ.ល)

## តារាងឧបសម្ព័ន្ធនៃគម្រោងផែនការលទ្ធកម្ម ប្រចាំឆ្នាំ...

## ទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា

ឯកតា:លានរៀល

| ល.រ | បរិយាយមុខសញ្ញាលទ្ធកម្ម | តម្លៃគម្រោង | វិធីសាស្ត្រលទ្ធកម្ម | កាលបរិច្ឆេទគ្រោងអនុវត្តគម្រោង | | កាលបរិច្ឆេទ គ្រោងទូទាត់ (ត្រីមាស) | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ចាប់ផ្តើម (ត្រីមាស) | បញ្ចប់ (ត្រីមាស) | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| **ក.លទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម** | | | | | | | |
| ក១ | អង្គភាពថវិកា (ឈ្មោះ) | | | | | | |
| | I-លទ្ធកម្មទំនិញ | | | | | | |
| 1 | 1- | | | | | | |
| 2 | 2- | | | | | | |
| សរុប I | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| | II-លទ្ធកម្មសំណង់ | | | | | | |
| 3 | 1- | | | | | | |
| 4 | 2- | | | | | | |
| សរុប II | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| | III-លទ្ធកម្មសេវាកម្ម | | | | | | |
| 5 | 1- | | | | | | |
| 6 | 2- | | | | | | |
| សរុប III | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុបក១ | តម្លៃគម្រោង : I+II+III | | | | | | |
| | ចំនួនគម្រោង : I+II+III | | | | | | |
| ក២ | អង្គភាពថវិកា (ឈ្មោះ) | | | | | | |
| | I-លទ្ធកម្មទំនិញ | | | | | | |
| 7 | 1- | | | | | | |
| 8 | 2- | | | | | | |
| សរុប I | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| | II-លទ្ធកម្មសំណង់ | | | | | | |
| 9 | 1- | | | | | | |
| 10 | 2- | | | | | | |
| សរុប II | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| | III-លទ្ធកម្មសេវាកម្ម | | | | | | |
| 11 | 1- | | | | | | |
| 12 | 2- | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សរុប III | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុបក២ | តម្លៃគម្រោង : I+II+III | | | | | | |
| | ចំនួនគម្រោង : I+II+III | | | | | | |
| សរុបលទ្ធ | តម្លៃគម្រោង : ក១+ក២+.. | | | | | | |
| កម្មទំនិញ | ចំនួនគម្រោង : ក១+ក២+.. | | | | | | |
| សរុបលទ្ធ | តម្លៃគម្រោង : ក១+ក២+.. | | | | | | |
| កម្មសំណង់ | ចំនួនគម្រោង : ក១+ក២+.. | | | | | | |
| សរុបលទ្ធ | តម្លៃគម្រោង : ក១+ក២+.. | | | | | | |
| កម្មសេវាកម្ម | ចំនួនគម្រោង : ក១+ក២+.. | | | | | | |
| សរុប ក | **តម្លៃគម្រោង : ក១+ក២+..** | | | | | | |
| | **ចំនួនគម្រោង : ក១+ក២+..** | | | | | | |
| **ខ.លទ្ធកម្មសេវាទីប្រឹក្សា** | | | | | | | |
| ខ១ | អង្គភាពថវិកា (ឈ្មោះ) | | | | | | |
| 1 | 1- | | | | | | |
| 2 | 2- | | | | | | |
| សរុបខ១ | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| ខ២ | អង្គភាពថវិកា (ឈ្មោះ) | | | | | | |
| 1 | 1- | | | | | | |
| 2 | 2- | | | | | | |
| សរុបខ២ | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុប ខ | **តម្លៃគម្រោង : ខ១+ខ២+..** | | | | | | |
| | **ចំនួនគម្រោង : ខ១+ខ២+..** | | | | | | |
| **គ.សរុបរួម** | | | | | | | |
| សរុប ក | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុប ខ | តម្លៃគម្រោង | | | | | | |
| | ចំនួនគម្រោង | | | | | | |
| សរុបរួម | **តម្លៃគម្រោង : ក+ខ** | | | | | | |
| | **ចំនួនគម្រោង : ក+ខ** | | | | | | |

បានពិនិត្យ និងឯកភាព

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦

..........ថ្ងៃទី ខែ ឆ្នាំ២០.......

**ប្រធាន(...ឈ្មោះស្ថាប័នអនុវត្តលទ្ធកម្ម...)**

**និងជាប្រធានគណកម្មាធិការលទ្ធកម្ម**

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦

............ថ្ងៃទី ខែ ឆ្នាំ២០......

**ប្រធានអង្គភាពលទ្ធកម្ម**